# មករៀននៅហ្វ៊ូគូអូកា!




## ហ្វ៊ូគូអូកាជាកន្លែងពេញនិយមមួយសម្រាប់និស្សិតបរទេស

បច្ចុប្បន្នមាននិស្សិតបរទេសចំនួន9000នាក់មកពី98ប្រទេសកំពុងសិក្សានៅខេត្តហ្វ៊ូគូអូកា។ហ្វ៊ូគូអូកាជាខេត្តមួយដែលមានចំនួននិស្សិតបរទេសច្រើនបំផុតទី៣ក្នុងប្រទេសជប៉ុន ហើយនឹងកំពុងបន្តកើនឡើងជាបន្តបន្ទាប់។

## មានសាកលវិទ្យាល័យល្បីៗជាច្រើន

ខេត្តហ្វ៊ូគូអូកាមានសាកលវិទ្យាល័យចំនួន38 (ក្នុងនោះមានសាកលវិទ្យាល័យបច្ចេកវិទ្យាចំនួន10) មហាវិទ្យាល័យបច្ចេកទេស(រយៈពេល2ឆ្នាំ)ចំនួន20 និងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន3។ សព្វថ្ងៃមាននិស្សិតសរុបចំនួន13ម៉ឺននាក់។

## ការចំណាយលើជីវភាពរស់នៅសមរម្យ

និស្សិតដែលរស់នៅខេត្តហ្វ៊ូគូអូកាចំណាយលើតម្លៃជីវភាពរស់នៅរួមនឹងថ្លៃសាលា មានតម្លៃទាបបើធៀបនឹងអត្រាចំណាយមធ្យមទូទាំងប្រទេស។តម្លៃជួលផ្ទះថោកជាងនៅតូក្យូ50%ហើយការចំណាយលើជីវភាពរស់នៅសរុបទាបជាង25%។



# មតិរបស់និស្សិតកម្ពុជាដែលសិក្សានៅខេត្តហ្វ៊ូគូអូកាអំពីការរស់នៅ និង ការសិក្សានៅហ្វ៊ូគូអូកា!!

លើកនេះសូមស្តាប់និស្សិតកម្ពុជាទាំង4នាក់ខាងក្រោម

**សេង ពិសិដ្ឋ** មកពីទីក្រុងភ្នំពេញ ជានិស្សិតផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាល័យគ្យូស្ យ៉ូ។ បន្ទាប់ពីបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យកម្ពុជា ពិសិដ្ឋបានទទួលអាហារូបករណ៍រាជរដ្ឋាភិបាលជប៉ុន ហើយបានមកបន្តការសិក្សានៅទីក្រុងហ្វ៊ូគូអូកា។

**Q. តើអ្នកយល់យ៉ាងណាចំពោះក្រុងហ្វ៊ូគូអូកា?**

**A.** ខ្ញុំយល់ថាហ្វ៊ូគូអូកាជាជំរើសដ៏ល្អបំផុតមួយសំរាប់ការសិក្សានៅជប៉ុន។ហ្វ៊ូគូអូកាជាទីក្រុងធំមួយរបស់ជប៉ុនដែលងាយស្រួលរស់នៅដោយសារការចំណាយសំរាប់ការរស់នៅមានកំរិតទាបជាងទីក្រុងធំៗដទៃទៀត អាកាសធាតុមិនសូវត្រជាក់ខ្លាំងហើយប្រជាជនហ្វ៊ូគូអូកាមានសន្តានចិត្តល្អនិងរួសរាយ។ នៅក្រុងហ្វ៊ូគូអូកាអ្នកអាចរកផ្ទះជួលដែលមានតម្លៃសមរម្យហើយនៅជិតបំផុតនឹងសាលារៀន ទីប្រជុំជន ផ្សារ ស្ថានីយ៍រថភ្លើងនិងកន្លែងកំសាន្តផ្សេងៗជាដើម។សណ្ឋានដីនៅហ្វ៊ូគូអូកាសម្បូរដោយវាលទំនាបងាយស្រួលធ្វើដំណើរហើយក៏ជាតំបន់ដែលសុវត្ថិភាពបំផុតមួយនៅជប៉ុនពាក់ព័ន្ធនឹងគ្រោះធម្មជាតិ។

ឈ្មោះ : សេង ពិសិដ្ឋ
ស្រុកកំណើត : ភ្នំពេញ
សាកលវិទ្យាល័យ : គ្យូស្យ៊ូ
មុខជំនាញ : សេដ្ឋកិច្ច



**ការប៉ាន់ស្មានចំណាយប្រចាំខែ**

អាហារូបករណ៍ : ≅ **1450**ដុល្លារ
ថ្លៃផ្ទះ : **200**ដុល្លារ
អាហារ : **300-400**ដុល្លារ
ទូរស័ព្ទ : **20-50**ដុល្លារ
ទឹកភ្លើងហ្គាស : **50-100**ដុល្លារ
ផ្សេងៗ : **200**ដុល្លារ



ឈ្មោះ : សែម សែងវថៃ
ស្រុកកំណើត : សៀមរាប
សាកលវិទ្យាល័យ : គ្យូស្យ៊ូ
មុខជំនាញ : ច្បាប់

**Q.តើអ្នកមានចំណាប់អារម្មណ៍យ៉ាងណាមុនពេលមកសិក្សានៅហ្វ៊ូគូអូកា?**

A.មុនពេលមកសិក្សានៅហ្វ៊ូគូអូកានាងខ្ញុំគិតថាហ្វ៊ូគូអូកាជាទីក្រុងមួយដែលងាយស្រួលរស់នៅមានទេសភាពស្រស់ស្អាតនិងម្ហូបអាហារឆ្ងាញ់ៗហើយជាតំបន់ទេសចរណ៍មួយដ៏សំខាន់មួយរបស់ជប៉ុន។

**Q.តើអ្នកមានចំណាប់អារម្មណ៍ដូចម្តេចក្រោយពេលបញ្ចប់ការសិក្សាពីហ្វ៊ូគូអូកា?**

A.ក្រោយពេលបញ្ចប់ការសិក្សាពីហ្វ៊ូគូអូកាខ្ញុំបានទទួលចំណេះដឹងបច្ចេកទេសច្បាប់ជាច្រើនដែលខ្ញុំមិនធ្លាប់បានរៀននៅប្រទេសខ្ញុំ។ម្យ៉ាងទៀតនៅទីនេះ នាងខ្ញុំបានស្គាល់មិត្តថ្មីៗជាច្រើនមកពីគ្រប់ប្រទេសដែលជាចំនុចដ៏ល្អសំរាប់ការទំនាក់ទំនងការងារទៅអនាគត។ខ្ញុំក៏បានសិក្សាស្វែងយល់ផងដែរអំពី វប្បធម៌និងអរិយធម៌ដ៏រុងរឿងរបស់ជនជាតិជប៉ុន។

**Q.តើអ្នកស្គាល់ហ្វ៊ូគូអូកាដោយសារអ្វី?**

**A.**ខ្ញុំបានស្គាល់ហ្វ៊ូគូអូកាតាមរយៈសិស្សច្បងដែលធ្លាប់បានមករៀននៅទីនេះ និងសាស្ត្រាចារ្យជប៉ុនដែលចុះទៅសិក្សាស្រាវជ្រាវនៅប្រទេសកម្ពុជា និងបន្ទាប់មកតាមការស្រាវជ្រាវបន្ថែមតាមអ៊ីនធឺណែតដោយខ្លួនឯង។

**Q.តើចំនុចអ្វីខ្លះដែលអ្នកពេញចិត្តចំពោះហ្វ៊ូគូអូកា?**

**A.**ហ្វ៊ូគូអូកាប្រមូលផ្តុំទៅដោយប្រជាជាតិមកពីច្រើនប្រទេស ដែលអាចឲ្យយើងផ្លាស់ប្តូរបទពិសោធន៍និងវប្បធម៌គ្នាបាន។ សន្តិសុខសុវត្ថិភាពក៏ជាកត្តាមួយទៀតដែលធ្វើឲ្យខ្ញុំពេញចិត្តទីក្រុងនេះដោយសារខ្ញុំជាមនុស្សស្រី ការធ្វើដំណើរពេលយប់គឺជារឿងពិបាក ប៉ុន្តែ នៅទីនេះខ្ញុំអាចធ្វើដំណើរពេលណាក៏បានដោយមិនមានការបារម្ភ។

ឈ្មោះ : ឌី វុទ្ធារ៉ា
ស្រុកកំណើត : ភ្នំពេញ
សាកលវិទ្យាល័យ : គ្យូស្យ៊ូ
មុខជំនាញ : គ្រប់គ្រងព្រៃឈើ



**Q.** សូមរៀបរាប់ពីការរបៀបប្រឡងមុនពេលមករៀននៅប្រទេសជប៉ុន?

**A.** បន្ទាប់ពីសំរេចចិត្តថាចង់ទៅរៀននៅប្រទេសជប៉ុនហើយ ខ្ញុំបានសើបសួរព័ត៌មានពីអ្នកដែលមានបទពិសោធន៍ និង និស្សិតដែលកំពុងសិក្សានៅទីនោះ រួចទៅសាកសួរព័ត៌មានពីនាយកដ្ឋានអាហារូបករណ៍នៃក្រសួងអប់រំ ដើម្បីយកពាក្យសុំប្រឡងមកបំពេញ។

1. ជ្រើសរើសវគ្គដែលចង់រៀនដែលមានដូចជា ថ្នាក់ក្រោយឧត្តមសិក្សា ថ្នាក់ឧត្តមសិក្សា ថ្នាក់មធ្យម និង ថ្នាក់បណ្តុះបណ្តាល។ខ្ញុំបានជ្រើសរើសថ្នាក់មធ្យមសិក្សា។
2. វិញ្ញាសាប្រឡងមានភាសាអង់គ្លេសនិងគណិតវិទ្យាដែលចេញដោយក្រសួងអប់រំ។
3. ពេលប្រឡងលើកទី១ជាប់ហើយនិងបន្តទៅប្រឡងគណិតវិទ្យា និង មុខវិជ្ជាជំនាញ រូបវិទ្យា ឬ គីមីវិទ្យាជាភាសាអង់គ្លេស។
4. បទសម្ភាសន៍ត្រូវធ្វើឡើងនៅស្ថានទូតជប៉ុននៅប្រទេសកម្ពុជា។
5. លទ្ធផលប្រឡងទាំងវគ្គធ្វើតេសន្តសរសេរ និង វគ្គផ្ទាល់មាត់រួមនិង លិខិតបញ្ជាក់សុខភាពបានត្រូវផ្ញើរទៅកាន់មហាវិទ្យាល័យ ឬ សាលានានានៅប្រទេសជប៉ុន ហើយលទ្ធផលចុងក្រោយនិងប្រកាសប្រាប់ទៅបេក្ខជនប្រឡងតាមរយៈស្ថានទូតជប៉ុនប្រចាំនៅកម្ពុជា។

ខ្ញុំនឹងចូលធ្វើការក្នុងក្រុមហ៊ុនជប៉ុនដើម្បីទទួលបានបទពិសោធន៍ក្នុងការងារ ហើយខ្ញុំនឹងខិតខំប្រឹងប្រែងដើម្បីឲ្យក្លាយជាអ្នកគ្រប់គ្រងម្នាក់។



ឈ្មោះ : ស្រី ចិន្តា
ស្រុកកំណើត : ភ្នំពេញ
សាកលវិទ្យាល័យ : គ្យូស្យូ
មុខជំនាញ : វិស្វករអគ្គិសនី



## សមាគមនិស្សិតខ្មែរនៅជប៉ុន តំបន់គ្យូស្យូ

សមាគមបង្កើតឡើងដើម្បីផ្តល់ការគាំទ្រគ្នាទៅវិញទៅមករវាងនិស្សិតខ្មែរដែលសិក្សានៅតំបន់គ្យូស្យូទាំងនិស្សិតមកសិក្សារយៈពេលវែងនិងមន្ត្រីរាជការកម្មសិក្សារយៈពេលខ្លី ព្រមទាំងបង្កើតកម្មវិធីមនុស្សធម៌នានាដើម្បីស្វែងរកជំនួយឧបត្ថមដល់សិស្សក្រីក្រនៅកម្ពុជា។ ម្យាងវិញទៀត ដើម្បីផ្សព្វផ្សាយពីវប្បធម៌និងទំនៀមទម្លាប់របស់ខ្មែរដល់ប្រជាជនជប៉ុនក្នុងតំបន់ សមាគមរៀបចំកម្មវិធីនិងព្រឹត្តិការណ៍ផ្សេងៗដើម្បីផ្លាស់ប្តូរវប្បធម៌និងលើកកំពស់ទំនាក់ទំនងល្អរវាងប្រទេសកម្ពុជានិងប្រទេសជប៉ុន។

E-mail: acsk_kyushu@yahoogroups.com
Website: www.csaj-khmer.org

FiSSC 福岡県留学生サポートセンター運営協議会
FUKUOKA INTERNATIONAL STUDENT SUPPORT CENTER

មជ្ឈមណ្ឌលសម្រាប់ជួយនិស្សិតបរទេស(FiSSC)ត្រូវបានបង្កើតឡើងក្នុងខែកក្កដាឆ្នាំ2008ក្នុងគោលបំណងគាំទ្រដល់និស្សិតបរទេសដែលរស់នៅក្នុងខេត្តហ្វ៊ូគូអូកា ដោយទទួលការឧបត្ថម្ភនិងគាំទ្រពីសាលាខេត្ត។

- ធ្វើសិក្ខាសាលាសិក្សា នៅបណ្តាប្រទេសនានា
- ជួយនិស្សិតកំពុងរៀនស្វែងរកការងារក្រៅម៉ោង
- ជួយនិស្សិតបញ្ចប់ការសិក្សា រកការងារធ្វើនៅប្រទេសជប៉ុន
- បង្កើតទំនាក់ទំនងល្អជាមួយនិស្សិតបញ្ចប់ការសិក្សានៅហ្វ៊ូគូអូកា

ទំនាក់ទំនងព័ត៌មាន
សមាគមអតីតនិស្សិតកម្ពុជានៅតំបន់ Fukuoka-Kyushu
ទូរស័ព្ទ:
+855-97-2911-333 /+855-12-697-776

Email:fissc09@gmail.com

FiSSC http://www.fissc.net/

# សាកលវិទ្យាល័យនៅក្នុងខេត្តហ្វ៊ូគូអូកា



**Kyushu University**
http://www.kyushu-u.ac.jp/english/index.php
✉ intlrkoryu@jimu.kyushu-u.ac.jp



**Kyushu Institute Of Technology**
http://www.kyutech.ac.jp/english/index.html
✉ kok-ryugaku@jimu.kyutech.ac.jp



**Fukuoka Women's University***
http://www.fwu.ac.jp/english/
✉ otsu@fwu.ac.jp



**The University of Kitakyushu**
http://www.kitakyu-u.ac.jp/another_language_site.html
✉ kkouryu@kitakyu-u.ac.jp



**Seinan Gakuin University**
http://www.seinan-gu.ac.jp/eng/
✉ intleduc@seinan-gu.ac.jp



**Fukuoka University**
http://www.fukuoka-u.ac.jp/english/
✉ kokusai@adm.fukuoka-u.ac.jp



**Kyushu Sangyo University**
http://www.ip.kyusan-u.ac.jp/E/index.html
✉ kokusai@ip.kyusan-u.ac.jp



**Fukuoka Institute of Technology**
http://www.fit.ac.jp/EN/index.html
✉ kokusai@fit.ac.jp



**Kurume University**
http://www.kurume-u.ac.jp/english/index.html
✉ kokusai@kurume-u.ac.jp



**Kinki University** Fukuoka Campus
Faculty of Humanity-Oriented Science and Engineering
http://www.fuk.kindai.ac.jp/ http://www.kindai.ac.jp/english/
✉ nyushi@fuk.kindai.ac.jp



**FUKUOKA JO GAKUIN University***
http://www.fukujo.ac.jp/university
✉ irc@fukujo.ac.jp

* សាកលវិទ្យាល័យសំរាប់តែនិស្សិតជាស្ត្រី